**នៅចំពោះមុខការិយាល័យសហចៅក្រមស៊ើបអង្កេត**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ៖ ០០៣/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស

ភាគីដាក់ឯកសារ៖ មេធាវីការពារក្តីរបស់ មាស មុត

ដាក់ជូន៖ សហចៅក្រមស៊ើបអង្កេត

ភាសាដើម៖ អង់គ្លេស

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី ៣១ ខែឧសភា ឆ្នាំ ២០១៦

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 08-June-2016, 08:00
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ៖ **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ៖ **សាធារណៈ**/Public

ចំណាត់ថ្នាក់ប្រភេទឯកសារៈ៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន៖

ឈ្មោះមន្ត្រីកត់ត្រា៖

ហត្ថលេខា៖

---

**សំណើរបស់ មាស មុត សុំអនុញ្ញាតដាក់ចម្លើយរួមចំនួន ១៥ ទំព័រ តបទៅនឹងសារណារបស់អ្នកដែលមិនមែនជាភាគីលើបញ្ហាដែលថា តើតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅឆ្នាំ ១៩៧៥-១៩៧៩ ការវាយប្រហារដោយរដ្ឋ ឬ អង្គការទៅលើកងកម្លាំងប្រដាប់អាវុធរបស់ខ្លួនផ្ទាល់ អាចជាការវាយប្រហារដែលសំដៅទៅលើប្រជាជនស៊ីវិល ឬយ៉ាងណា**

---

**ដាក់ដោយ:**

**សហមេធាវី៖**

អាង ឧត្តម

Michael G. KARNAVAS

**ផ្ញើជូន:**

**សហចៅក្រមស៊ើបអង្កេត៖**

ចៅក្រម យូ ប៊ុនឡេង

ចៅក្រម Michael BOHLANDER

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Nicholas KOUMJIAN

**ភាគីដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

លោក មាស មុត តាមរយៈសហមេធាវីរបស់គាត់ ("មេធាវីការពារក្តី") តាមរយៈនេះ សុំអនុញ្ញាតដាក់ចម្លើយរួមចំនួន ១៥ ទំព័រ តបទៅនឹងសារណារបស់ *អ្នកដែលមិនមែនជាភាគី* លើបញ្ហាថាតើ "តាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដែលអនុវត្តនៅឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ការវាយប្រហារដោយរដ្ឋ ឬអង្គការទៅលើសមាជិកនៃកងកម្លាំងប្រដាប់អាវុធរបស់ *ខ្លួនផ្ទាល់* អាចជាការវាយប្រហារដែលសំដៅទៅលើប្រជាជនស៊ីវិល ឬយ៉ាងណា..."[1]។ នៅក្នុងជម្រើសផ្សេងទៀត ប្រសិនបើក្រុមមេធាវីការពារក្តី ០០៤ ណាមួយ ជ្រើសរើសមិនឆ្លើយតបទៅនឹងសារណារបស់ *អ្នកដែលមិនមែនជាភាគី* មេធាវីការពារក្តីស្នើសុំឱ្យបន្ថែមចំនួនពាក្យកំណត់សម្រាប់ក្រុមនោះទៅលើចំនួនពាក្យកំណត់ ៣០០០ របស់មេធាវីការពារក្តីដែលដាក់ដោយសហចៅក្រមស៊ើបអង្កេតសម្រាប់ចម្លើយរួម។ ដោយសារភាពបន្ទាន់នៃសំណើ សំណើនេះត្រូវបានដាក់ជាភាសាអង់គ្លេសសិន ដោយដាក់ភាសាខ្មែរជូនតាមក្រោយភ្លាម នៅពេលដែលការបកប្រែត្រូវបានបញ្ចប់។

១. មាត្រា ៥.១ នៃសេចក្តីណែនាំអនុវត្តស្តីអំពីការដាក់ឯកសារនៅ អ.វ.ត.ក. ចែងថា ភាគីមានចំនួនទំព័រកំណត់ ១៥ ទំព័រ សម្រាប់សារណាដែលដាក់នៅចំពោះមុខការិយាល័យសហចៅក្រមស៊ើបអង្កេត លើកលែងតែមានបញ្ហាផ្សេងចេញដោយ អ.វ.ត.ក.។ *អ្នកដែលមិនមែនជាភាគី* ចំនួនដប់មួយ បានដាក់សារណាអនុលោមតាមសេចក្តីអំពាវនាវឱ្យដាក់សារណា[2]។ ជាជាងអនុញ្ញាតឱ្យភាគី

---

[1] សេចក្តីអំពាវនាវសុំឱ្យដាក់សារណាពីភាគីនៅក្នុងសំណុំរឿង ០០៣ និង ០០៤ និង *អ្នកដែលមិនមែនជាភាគី* ចុះថ្ងៃទី ១៩ ខែមេសា ឆ្នាំ ២០១៦ ឯកសារ D191 ("សេចក្តីអំពាវនាវសុំឱ្យដាក់សារណា") កថាខណ្ឌ ៣។

[2] សារណារបស់ *អ្នកដែលមិនមែនជាភាគី* នៅក្នុងរឿងក្តី ០០៣ និង ០០៤ – សាស្ត្រាចារ្យ Ben Saul ចុះថ្ងៃទី ១៩ ខែឧសភា ឆ្នាំ ២០១៦ ឯកសារ D191/3។ សារណារបស់ *អ្នកដែលមិនមែនជាភាគី* សម្រាប់រឿងក្តី ០០៣ និង ០០៤ ចុះថ្ងៃទី ១៩ ខែឧសភា ឆ្នាំ ២០១៦ ឯកសារ D191/4។ សារណារបស់ *អ្នកដែលមិនមែនជាភាគី* ចុះថ្ងៃទី ១៩ ខែឧសភា ឆ្នាំ ២០១៦ ឯកសារ D191/5។ សារណារបស់អ្នកដែលមិនមែនជាភាគីរបស់សាស្ត្រាចារ្យ Robinson, deGuzman, Jalloh និង Cryer ស្តីពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ (រឿងក្តី ០០៣ និង ០០៤) ចុះថ្ងៃទី ១៧ ខែឧសភា ឆ្នាំ ២០១៦ ឯកសារ D191/6។សារណារបស់ Ido Rosenzweig ចុះថ្ងៃទី ១៩ ខែឧសភា ឆ្នាំ ២០១៦ ឯកសារ D191/7។ សារណារបស់បណ្ឌិត Joanna Nicholson ជា *អ្នកដែលមិនមែនជាភាគី* ដោយមិនគាំទ្រភាគីណាមួយ ចុះថ្ងៃទី ១៩ ខែឧសភា ឆ្នាំ ២០១៦ ឯកសារ D191/8។*អ្នកដែលមិនមែនជាភាគី* សម្រាប់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី ១៧ ខែឧសភា ឆ្នាំ ២០១៦ ឯកសារ D191/9។ សារណារបស់ *អ្នកដែលមិនមែនជាភាគី* ឆ្លើយតបទៅនឹងសេចក្តីអំពាវនាវសុំឱ្យដាក់សារណា [sic] ពីភាគីនៅក្នុងសំណុំរឿង ០០៣ និង ០០៤ និង *អ្នកដែលមិនមែនជាភាគី* ចុះថ្ងៃទី ១៩ ខែឧសភា ឆ្នាំ ២០១៦ ឯកសារ D191/10។ សារណារបស់*អ្នកដែលមិនមែនជាភាគី* ដែលដាក់ដោយបណ្ឌិត Williams និង Grey ឆ្លើយតបទៅនឹងសេចក្តីអំពាវនាវសុំឱ្យដាក់សារណារបស់ *អ្នកដែលមិនមែនជាភាគី* នៅក្នុងសំណុំរឿង ០០៣ និង ០០៤ ចុះថ្ងៃទី ១៩ ខែមេសា [sic] ឆ្នាំ ២០១៦ D191/11។ សារណារបស់អ្នកដែលមិនមែនជាភាគីដាក់ដោយមជ្ឈមណ្ឌលច្បាប់អន្តរជាតិប្រៀបធៀប (the Center for International and Comparative Law)

ដាក់ចម្លើយ ដែលមានចំនួន ១៥ ទំព័រ តបទៅនឹងសារណាទាំងនេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានជូនដំណឹងភាគីថា "ចម្លើយរួម [តបទៅនឹងសារណារបស់ *អ្នកដែលមិនមែនជាភាគី*] មិនត្រូវលើសពី ចំនួន ៣០០០ ពាក្យនោះទេ (រាប់បញ្ចូលទាំងជើងទំព័រ)"[3] ។

២. មេធាវីការពារក្តីមិនអាចឆ្លើយតបឲ្យបានពេញលេញទៅនឹងសារណាចំនួន ១១ របស់ *អ្នកដែលមិនមែនជាភាគី* ដែលសរុបមានប្រហែលជា ៣៣០០០ ពាក្យ នៅក្នុងសារណាតែមួយដែលមានចំនួន ៣០០០ ពាក្យនោះទេ។ បញ្ហាដែលលើកឡើងនៅក្នុងសេចក្តីអំពាវនាវសុំឲ្យដាក់សារណា គឺស្មុគស្មាញ ហើយដំណោះស្រាយត្រឹមត្រូវ គឺសំខាន់ណាស់សម្រាប់រឿងក្តីរបស់លោក មាស មុត។ សហមេធាវីរបស់គាត់ នឹងមិនអាចបំពេញកិច្ចដោយយកចិត្តទុកដាក់បានទេ ប្រសិនបើពួកគេមិនបានឆ្លើយតបឲ្យបានពេញលេញទៅនឹងទឡ្ហីករណ៍របស់ *អ្នកដែលមិនមែនជាភាគី* នោះ។ ចម្លើយរួមចំនួន ១៥ ទំព័រ គួរតែគ្រប់គ្រាន់ សម្រាប់តបទៅនឹងទឡ្ហីករណ៍ដែលលើកឡើងដោយ *អ្នកដែលមិនមែនជាភាគី* ទាំង ១១ នោះ ដោយមិនដាក់បន្ទុកហួសហេតុទៅលើអង្គភាពបកប្រែភាសា។ ការិយាល័យសហព្រះរាជអាជ្ញានឹងមិនទទួលរងព្យសនកម្មដោយសារសំណើនេះទេ។ ការិយាល័យនេះអាចស្នើសុំចំនួនទំព័របន្ថែម ប្រសិនបើការបន្ថែមនេះជាការចាំបាច់។

៣. ប្រសិនបើសហចៅក្រមស៊ើបអង្កេតមិនចង់អនុញ្ញាតឲ្យមេធាវីការពារក្តីដាក់ចម្លើយរួមចំនួន ១៥ ទំព័រ មេធាវីការពារក្តីគួរទទួលបានការអនុញ្ញាតឲ្យប្រើប្រាស់ចំនួនកំណត់ ៣០០០ ពាក្យរបស់ក្រុមមេធាវីការពារក្តី ០០៤ បន្ថែមទៅលើចំនួនពាក្យកំណត់របស់មេធាវីការពារក្តី ប្រសិនបើក្រុមមេធាវីការពារក្តី ០០៤ ណាមួយ មានចេតនាមិនចង់រៀបចំចម្លើយរបស់ខ្លួនផ្ទាល់នោះ។ នេះនឹងជួយដល់សហមេធាវីនៅក្នុងការបំពេញកាតព្វកិច្ចយកចិត្តទុកដាក់យ៉ាងខ្ជាប់ខ្ជួនចំពោះលោក មាស មុត ដោយគ្មានការបន្ថែមបន្ទុកណាមួយទៅលើអង្គភាពបកប្រែភាសា។

---

សាកលវិទ្យាល័យច្បាប់ Baltimore ស្តីពីនីត្យានុកូលភាពនៃគោលដៅសមាជិកយោធារបស់ខ្លួនផ្ទាល់ ចុះថ្ងៃទី ១៨ ខែឧសភា ឆ្នាំ ២០១៦ ឯកសារ D191/12។ មជ្ឈមណ្ឌលសិទ្ធិមនុស្សនៃសាកលវិទ្យាល័យស្តេចស្រី Belfast (Queen's University Belfast Human Rights Centre) ចម្លើយតបទៅនឹងការិយាល័យសហចៅក្រមស៊ើបអង្កេត អ.វ.ត.ក. "សេចក្តីអំពាវនាវសុំឲ្យដាក់សារណាពីភាគីនៅក្នុងសំណុំរឿង ០០៣ និង ០០៤ និង អ្នកដែលមិនមែនជាភាគី" ចុះថ្ងៃទី ១២ ខែឧសភា ឆ្នាំ ២០១៦ ឯកសារ D191/13។

[3] កថាខណ្ឌ ១៣ នៃសេចក្តីអំពាវនាវសុំឲ្យដាក់សារណា។

**អាស្រ័យហេតុនេះ** យោងតាមសំអាងហេតុទាំងអស់ដែលបានលើកឡើងខាងលើ មេធាវីការពារក្តីគោរពស្នើសុំការអនុញ្ញាតឱ្យដាក់ចម្លើយរួមចំនួន ១៥ ទំព័រ តបទៅនឹងសារណារបស់ *អ្នកដែលមិនមែនជាភាគី* ឬ ក្នុងជម្រើសផ្សេងទៀត ស្នើសុំឱ្យផ្តល់ឱ្យមេធាវីការពារក្តីនូវពាក្យចំនួន ៣០០០ របស់ក្រុមមេធាវីការពារក្តី ០០៤ ប្រសិនបើក្រុមណាមួយនៃក្រុមមេធាវីការពារក្តី ០០៤ សម្រេចមិនឆ្លើយតបទៅនឹង *អ្នកដែលមិនមែនជាភាគី*។

សូមលោកចៅក្រមមេត្តាទទួលយកសំណើនេះដោយក្តីគោរព។

ធ្វើនៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី **៣១** ខែ**ឧសភា** ឆ្នាំ **២០១៦**

សហមេធាវីការពារក្តីលោក មាស មុត

| | |
|---|---|
| __________ | __________ |
| អាង ឧត្តម | Michael G. KARNAVAS |